# កិច្ចព្រមព្រៀង
# រវាង
# ក្រុមហ៊ុន ស៊ូភៀល (ខេមបូឌា) ឯ.ក
# និង
# ជាមួយសហជីពនិងតំណាងកម្មករនិយោជិតប្រចាំក្រុមហ៊ុន

នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង ១០: ៣០ នាទី ព្រឹក នៅក្នុងក្រុមហ៊ុន ស៊ូភៀល (ខេមបូឌា) ឯ.ក មានកិច្ចប្រជុំមួយ រវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករនិយោជិត ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់ កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រថា ដោយសារតែក្រុមហ៊ុនយើងខ្វះវត្ថុធាតុដើម ដែលជាហេតុមិនអាចអោយសង្វាក់ផលិតកម្មដំណើរការបាន។ ហេតុដូចនេះ ក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ១៦៥៣ នាក់ (ស្រី១១៩១ នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ១៦៥៣នាក់ (ស្រី ១១៩១នាក់) រយៈពេលព្យួរចំនួន ១៥ ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី ១ ខែ តុលា ឆ្នាំ២០២៣ ដល់ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ២០២៣។ ហើយនៅក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ កម្មករនិយោជិត បានឯកភាពទទួលការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឈ្នួល ៣០ ដុល្លារអាមេរិចក្នុងថ្ងៃព្យួរ ។ ប្រាក់ឈ្នួលនេះនិងបើកជូននៅ ថ្ងៃសៅរ៍ ទី៣០ ខែកញ្ញា ឆ្នាំ២០២៣ សម្រាប់កម្មករនិយោជិតម្នាក់ៗ ។

អង្គប្រជុំបានចប់នៅវេលាម៉ោង ១០: ៥០ នាទី ព្រឹក នាថ្ងៃខែឆ្នាំដដែល ដោយភាគីទាំងសងខាងមានភាពស្និតស្នាល និងយោគយល់ និងសហការគ្នាយ៉ាងរលូន។

ថ្ងៃអង្គារ ១២រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

កំពង់ស្ពឺ, ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣

ជ. **នាយកក្រុមហ៊ុន**

ក្រុមហ៊ុន ស៊ូភៀល (ខេមបូឌា) ឯ.ក រដ្ឋបាល H.R.D SUPERL (CAMBODIA) CO.,LTD

**ស្នាមមេដៃតំណាងកម្មករនិយោជិត**

| | | | | | | |
|---|---|---|---|---|---|---|
| ចន សុផា | ស្រ៊ាន់ ស្រស់ | វ៉ាន់ សុខណា | សាំ កញ្ញា | យ៉េង ម៉ៅ | កង សេទ្ធា | អ៊ុន ចាន់ឌី |
| តាក វ៉ារិច | កង ពិសិដ្ឋ | សាយច័ន្ទរស្មី | លន់ ប៉េងលី | កាញ់ ចាន់ថា | សាធ ប៊ុនភួន | |